# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...១៤៥...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងនីតិបុគ្គលសាធារណៈ
- លិខិតលេខ៨៩៥សជណ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ១០២២សជណ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ៦៧៨សជណ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ២៨៧២កសក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ

## សម្រេច

**មាត្រា១៖**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋលើផ្ទៃដីមួយចំនួនដូចខាងក្រោម៖

១-លើផ្ទៃដីទំហំ ២ ០៩៥,១៧ ហិកតា (ពីរពាន់កៅសិបប្រាំក្បៀសដប់ប្រាំពីរហិកតា )ដែលមានទីតាំងស្ថិតនៅក្នុងឃុំរលួសមានជ័យ និងឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ របស់ក្រុមហ៊ុន ដុង ណាយ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ (គម្រោងទី១)សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានប្លង់ទីតាំងសម្បទានដីសេដ្ឋកិច្ច ក្រចេះ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់អភិបាលខេត្តក្រចេះ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១៤ប័ណ្ណ ក្រចេះ. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ ។

២-លើផ្ទៃដីទំហំ ៤ ៤២៨,៣៣ ហិកតា (បួនពាន់បួនរយម្ភៃប្រាំក្បៀសសាមសិបបីហិកតា )ដែលមានទីតាំងស្ថិតនៅក្នុងឃុំអូគ្រៀង និងឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ របស់ក្រុមហ៊ុន ដុង ណាយ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ (គម្រោងទី២)សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានប្លង់ទីតាំងសម្បទានដីសេដ្ឋកិច្ច ក្រចេះ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់អភិបាលខេត្តក្រចេះ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១៥ប័ណ្ណ ក្រចេះ. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ ។

៣-លើផ្ទៃដីទំហំ ១ ៩៤៩,៤៦ ហិកតា (មួយពាន់ប្រាំបួនរយសែសិបប្រាំបួនក្បៀសសែសិបប្រាំមួយហិកតា ) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសំបូរ ខេត្តក្រចេះ របស់ក្រុមហ៊ុន ដុង ភូ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ (គម្រោងទី១) នៅក្នុងឃុំរលួសមានជ័យ និងឃុំអូគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ របស់ក្រុមហ៊ុន ដុង ភូ ក្រចេះ អភិវឌ្ឍន៍កៅស៊ូ (គម្រោងទី១)សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានប្លង់ទីតាំងសម្បទានដីសេដ្ឋកិច្ច ក្រចេះ. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២ របស់អភិបាលខេត្តក្រចេះ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១៥ប័ណ្ណ ក្រចេះ. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៣ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តក្រចេះ ។

៤-លើផ្ទៃដីទំហំ ៥ ២៧២,៣៣ ហិកតា (ប្រាំពាន់ពីររយចិតសិបពីរក្បៀសសាមសិបបីហិកតា ) ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ របស់ក្រុមហ៊ុន ស៊ី អ ស៊ី ខេ អភិវឌ្ឍន៍កៅស៊ូ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានប្លង់ទីតាំងសម្បទានដីសេដ្ឋកិច្ច កំពង់ធំ. ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ របស់អភិបាលខេត្តកំពង់ធំ និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ១៦ប័ណ្ណ កំពង់ធំ. ចុះថ្ងៃទី ខែ ឆ្នាំ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ ។

៥-លើផ្ទៃដីទំហំ ៦ ០៥១,៦០ ហិកតា (ប្រាំមួយពាន់ហាសិបមួយក្បៀសហុកសិបហិកតា )ដែលមានទីតាំងស្ថិតនៅក្នុងស្រុកអណ្តូងមាស និងស្រុកតាវែង ខេត្តរតនគិរី របស់ក្រុមហ៊ុន ក្រុង ប៊ុក រតនគិរី អភិវឌ្ឍន៍កៅស៊ូ សម្រាប់គោលដៅសម្បទានដីសេដ្ឋកិច្ច ដូចមានប្លង់ទីតាំងសម្បទានដីសេដ្ឋកិច្ច រតនគិរី. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ របស់អភិបាលខេត្តរតនគិរី និងប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុចំនួន ២៣ប័ណ្ណ រតនគិរី. ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៦ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តរតនគិរី ។

**មាត្រា២៖**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតនៅក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ និងគោលការណ៍កំណត់របស់រាជរដ្ឋាភិបាល។

**មាត្រា៣៖**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤៖**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ,ខេត្តកំពង់ធំ និងខេត្តរតនគិរី ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល៖</u>

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ